ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៩ លេខ ៣ | ខែកញ្ញា ២០១៥ | តម្លៃ ១.៥០០៛

# ភាពគ្មានដីធ្លី និងពលកម្មកុមារនៅកម្ពុជា

## សេចក្ដីផ្ដើម

ពលកម្មកុមារ ឃើញមានច្រើនពាសពេញនៅកម្ពុជា ហើយនៅតែមានបន្តទៅទៀត៖ កុមារអាយុពី ៥ ទៅ ១៧ឆ្នាំ រហូតដល់ ៧៥៥.២៥០នាក់ (១៩% នៃកុមារសរុប) កំពុងបម្រើការងារ ក្នុងនោះ ៣០% បម្រើការងារមានគ្រោះថ្នាក់ ដូចជា ការជួញដូរផ្លូវភេទ ការជួញដូរថ្នាំញៀន ឬក៏ត្រូវគេជួញដូរ (NIS និង ILO 2013)។

ពលកម្មកុមារនៅកម្ពុជា ជាបញ្ហាចោទនៅទីជនបទ។ កុមារភាគច្រើនកំពុងបម្រើការងារ ដូចជា ការនេសាទ ចិញ្ចឹមសត្វ ដាំដំណាំ រកអុស និង ក្នុងលក្ខណៈជាអ្នកជួយក្រុមគ្រួសារដោយគ្មានប្រាក់កម្រៃ ហើយជួនកាលធ្វើជាពលករក្នុងវិស័យក្រៅផ្លូវការ ប៉ុន្ដែមានតិចជាង ២% ដែលធ្វើការក្នុងរោងអាជីវកម្មខ្វះសុវត្ថិភាព និងផ្ដល់ប្រាក់កម្រៃទាប (NIS 2004, 11)។ ការប្រើពលកម្មកុមារ ជាការរកចំណូលបន្ថែម និងបំពេញកង្វះកម្លាំងពលកម្ម សម្រាប់គ្រួសារ មិនមែនសម្រាប់ជំនួសកម្លាំងពលកម្មពេញវ័យនោះទេ (Siddiqui 2012)។ ភាពគ្មានដីធ្លី ឬស្ទើរគ្មានដីធ្លី ជាមូលហេតុចម្បងមួយនៃភាពក្រីក្រនៅជនបទ៖ ការគ្មានដី ឬមានដីតូចពេកសម្រាប់ប្រើប្រាស់ វានាំឲ្យចំណូលគ្រួសារមានការខ្វះខាត។ ជាយុទ្ធសាស្ត្រដើម្បីដោះស្រាយជីវភាពសាម៉ីគ្រួសារក៏បញ្ជូនកូនៗឲ្យទៅធ្វើការ។

ចំណេះដឹងស្ដីពីទំនាក់ទំនងរវាង ភាពគ្មានដីធ្លី នឹងពលកម្មកុមារ នៅមានកម្រិតនៅឡើយ។ អត្ថបទនេះ ពិនិត្យពីកង្វះខាតទាំងឡាយក្នុងការសិក្សាកន្លងមក ដោយព្យាយាមឆ្លើយនឹងសំណួរដូចខាងក្រោម៖

១. តើភាពគ្មានដីធ្លី ជាប់ទាក់ទងយ៉ាងដូចម្ដេចទៅនឹង ពលកម្មកុមារ ?
២. តើស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច និងសុខុមាលភាពកុមារមានលក្ខណៈខុសគ្នាយ៉ាងណារវាងគ្រួសារគ្មានដីធ្លី និងគ្រួសារមានដីកាន់កាប់ ?
៣. តើក្មេងប្រុស និងក្មេងស្រី យល់យ៉ាងណាដែរពី តួនាទីរបស់ខ្លួនក្នុងការជួយផ្គត់ផ្គង់ជីវភាពគ្រួសារ ?



*ពលកម្មកុមារនៅកម្ពុជា ជាបញ្ហាចោទនៅទីជនបទ ខេត្តតាកែវ ឧសភា ២០១៥។*

## និយមន័យពលកម្មកុមារ និងភាពគ្មានដីធ្លី

ពលកម្មកុមារ៖ ក្រសួងផែនការ (2012) ស្របតាមច្បាប់ស្ដីពីការងាររបស់ប្រទេសកម្ពុជា (អនុម័តនៅឆ្នាំ១៩៩៧) បានកំណត់និយមន័យ ពលកម្មកុមារ ថាជា ទម្រង់ណាមួយនៃសកម្មភាពសេដ្ឋកិច្ច ឬមិនមែនសេដ្ឋកិច្ច ចាប់ពី ១ម៉ោងក្នុងមួយសប្ដាហ៍ឡើងទៅ ដែលអាចធ្វើឲ្យខូចខាតដល់សុខភាព ឬការរីកលូតលាស់រាងកាយ សតិបញ្ញា ស្មារតី សីលធម៌ ឬស្ថានភាពក្នុង

## មាតិកា

ភាពគ្មានដីធ្លី និងពលកម្មកុមារនៅកម្ពុជា ............ ១
ការធ្វើផែនការគ្រប់គ្រងគ្រោះមហន្តរាយ
  នៅជនបទកម្ពុជា ............ ៥
តាមដានសេដ្ឋកិច្ច – ស្ថានភាពក្រៅប្រទេស ............ ១០
  – ស្ថានភាពក្នុងប្រទេស ............ ១២
  – សូចនាករ ............ ១៤
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ............ ២០

---

អត្ថបទនេះប្រើប្រាស់លទ្ធផលបានពីការសិក្សារបស់ CDRI (Phann et al. 2014) មាននៅក្នុង www.ehs.unu.edu/file/get/9018។ សូមយោងអត្ថបទនេះថា Phann Dalis. 2015. "Landlessness and Child Labour in Cambodia." *Cambodia Development Review* 19(3): 1-4. Phnom Penh: CDRI.

សង្គមរបស់កុមារ។ ច្បាប់ស្ដីពីការងារ បានកំណត់អាយុធ្វើការទាបបំផុតត្រឹម ១៥ឆ្នាំ ប៉ុន្តែអនុញ្ញាតឲ្យកុមារអាយុពី ១២ ទៅ ១៤ឆ្នាំ ធ្វើការងារស្រាលៗបានរហូតដល់ ១៤ម៉ោងក្នុងមួយសប្ដាហ៍។

តារាង១៖ ចំនួនម៉ោងធ្វើការក្នុងនិយមន័យពលកម្មកុមារ

| ក្រុមអាយុ | គ្មានគ្រោះថ្នាក់ | មានគ្រោះថ្នាក់ |
|---|---|---|
| ៥-១១ | ≥ ១ ម៉ោង/សប្ដាហ៍ | |
| ១២-១៤ | ≥ ១៤ ម៉ោង/សប្ដាហ៍ | សូម្បីតែ ≤ ១៤ ម៉ោង/សប្ដាហ៍ |

សំគាល់៖ ការងារមានគ្រោះថ្នាក់ តាមនិយមន័យកំណត់ក្នុង (ILO 2002, 34) គឺ៖
- ការងារដែលធ្វើឲ្យកុមារ ត្រូវប៉ះជួបនឹងការបៀតបៀនរាងកាយ ផ្លូវចិត្ត ឬផ្លូវភេទ ឬក៏ រងការប៉ះពាល់ដោយកំដៅ កម្រិតសម្លេងរំខាន ឬរំញ័រ ដែលធ្វើឲ្យខូចសុខភាព
- ការងារនៅក្រោមដី ក្រោមទឹក នៅកន្លែងខ្ពស់អាចមានគ្រោះថ្នាក់ ឬក្នុងកន្លែងតូចចង្អៀត
- ការងារអនុវត្តជាមួយគ្រឿងចក្រ បរិក្ខារ និងឧបករណ៍ងាយបង្កគ្រោះថ្នាក់ ឬ ការងារលើសែងធ្ងន់ៗ ឬការងារច្រើនម៉ោងនៅពេលយប់។

ភាពគ្មានដីធ្លី៖ គ្រួសារគ្មានដី គឺគ្រួសារគ្មានដីកសិកម្ម ទោះដោយសារហេតុផលអ្វីក៏ដោយ។

## វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាបានប្រើទាំងវិធីសាស្ត្របែបបរិមាណ និងបែបគុណភាព រួមបញ្ចូលគ្នា។ វិធីសាស្ត្រស្រាវជ្រាវ បែបគុណភាព រួមមាន ការធ្វើសម្ភាសន៍ស៊ីជម្រៅដើម្បីប្រមូលព័ត៌មានលើប្រវត្តិ គំនិត និងបទពិសោធន៍របស់បុគ្គល និងកិច្ចពិភាក្សាតាមក្រុមស្នូល ដើម្បីប្រមូលគំនិតឲ្យបានកាន់តែទូលំទូលាយ លើបញ្ហាគួរចាប់អារម្មណ៍។ ព័ត៌មានប្រមូលបានមិនតំណាងឲ្យគំនិតជារួមរបស់មនុស្សពេញវ័យ និងកុមារនៅកម្ពុជានោះទេ ប៉ុន្តែជាមតិរបស់អ្នកចូលរួមនានានៅតាមភូមិបានជ្រើសរើស។

ការវិភាគបែបបរិមាណ ផ្អែកលើទិន្នន័យបានពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ២០០៤, ២០០៧, ២០០៩ និង ២០១១ ដែលតំណាងឲ្យទូទាំងប្រទេស។ ការវិភាគបែបគុណភាពផ្អែកជាសំខាន់លើ ការចុះសិក្សាដល់កន្លែងនៅតាមខេត្តពោធិ៍សាត់ ឧត្ដរមានជ័យ ព្រះវិហារ ក្រចេះ កោះកុង ក្នុងឆ្នាំ២០១៤។ ក្រុមស្រាវជ្រាវបានជ្រើសយក ២ភូមិក្នុងខេត្តនីមួយៗ ហើយក្នុងភូមិនីមួយៗបានធ្វើការពិភាក្សាតាមក្រុមស្នូល ២, សម្ភាសន៍ស៊ីជម្រៅ ៣ និងសម្ភាសន៍អ្នកផ្ដល់ព័ត៌មានគន្លឹះ ១។ ដោយមានការពិគ្រោះយោបល់ជាមួយមេភូមិ ក្រុមស្រាវជ្រាវបានជ្រើសរើសសំណាកចេញពីគ្រួសារ ៤ប្រភេទ៖ ក្រីក្រមានដីកសិកម្ម, ក្រីក្រគ្មានដីកសិកម្ម, មិនក្រីក្រមានដីកសិកម្ម និងមិនក្រីក្រគ្មានដីកសិកម្ម។

## ភាពគ្មានដីធ្លី

ការសិក្សាបានស្វែងរកមូលហេតុនៃភាពគ្មានដីធ្លី ដោយផ្អែកលើអង្កេតមួយក្នុងឆ្នាំ២០១៤ លើចលករនៃភាពក្រីក្ររបស់ ១១៨៣គ្រួសារ ក្នុង ១១ភូមិ នៅតាមជនបទក្នុង ៩ខេត្ត មាន

តារាង២: ពលកម្មកុមារគិតតាមតំបន់ ឆ្នាំ២០០៤-១១

| | 2004 | 2007 | 2008 | 2009 | 2010 | 2011 |
|---|---|---|---|---|---|---|
| **កុមារអាយុពី ៥-១៤ឆ្នាំ** | **15603** | **4024** | **3632** | **12674** | **3348** | **3287** |
| ភ្នំពេញ | 1107 | 634 | 583 | 884 | 533 | 513 |
| ក្រុងដទៃទៀត | 2178 | 743 | 652 | 1286 | 579 | 599 |
| ជនបទ | 12318 | 2647 | 2397 | 10504 | 2236 | 2175 |
| ***ភាគរយនៃពលកម្មកុមារ*** | | | | | | |
| **ពលកម្មកុមារសរុប** | **21.8** | **23.3** | **21.1** | **25.1** | **18.6** | **18.7** |
| ភ្នំពេញ | 6.1 | 5.2 | 4.6 | 3.2 | 3.0 | 1.6 |
| ក្រុងដទៃទៀត | 15.8 | 14.3 | 14.4 | 11.0 | 9.0 | 9.0 |
| ជនបទ | 24.3 | 30.2 | 27.0 | 28.6 | 24.8 | 25.4 |

ប្រភព: CSES 2004-11

តារាង៣: វត្តមានពលកម្មកុមារ គិតតាមទំហំដីរបស់គ្រួសារធ្វើកសិកម្ម ឆ្នាំ២០០៤-១១ (%)

| | 2004 | 2007 | 2008 | 2009 | 2010 | 2011 |
|---|---|---|---|---|---|---|
| គ្រួសារគ្មានដី (ដី=0) | 18.9 | 20.0 | 17.1 | 19.1 | 18.3 | 20.7 |
| <1 ហិកតា | 25.9 | 29.7 | 26.4 | 29.0 | 24.7 | 23.9 |
| 1-2 ហិកតា | 29.6 | 34.6 | 33.0 | 34.1 | 25.4 | 30.1 |
| 2-3 ហិកតា | 30.3 | 39.4 | 26.8 | 29.6 | 31.0 | 28.4 |
| >3 ហិកតា | 28.9 | 33.3 | 35.7 | 32.5 | 25.1 | 28.2 |

ប្រភព: CSES 2004-11

បាត់ដំបង កំពង់ធំ ក្រចេះ កំពត កណ្ដាល ព្រៃវែង កំពង់ស្ពឺ ព្រះសីហនុ និង ព្រះវិហារ។ លទ្ធផលអង្កេតបង្ហាញថា គ្រួសារគ្មានដីធ្លីភាគច្រើនបំផុត មិនដែលមានដីធ្លីទេ។ មូលហេតុដទៃទៀត គឺការលក់ដី ការផ្ទេរដីឲ្យកូន ការផ្លាស់កន្លែង ការទន្ទ្រានយកដី ជាដើម។ គ្រួសារគ្មានដីកសិកម្មប្រមូលផ្ដុំភាគច្រើននៅតំបន់ទីក្រុង និងតំណាងឲ្យ ២៨% នៃគ្រួសារសរុបនៅចន្លោះឆ្នាំ២០០៤ និង ២០១១។ ពួកគេជាទូទៅប្រកបការងារក្នុងវិស័យសេវាកម្ម មានស្ថានភាពធូរធារជាងគ្រួសារមានដីកាន់កាប់ ហើយមេគ្រួសារតែងសម្រេចបានកម្រិតអប់រំខ្ពស់ជាង។

## វត្តមានពលកម្មកុមារ

ទិន្នន័យបានពី CSES (តារាង២) បង្ហាញថា ពលកម្មកុមារតែងឃើញមានច្រើនជាង ក្នុងគ្រួសារនៅតាមតំបន់ជនបទក្នុងអំឡុងឆ្នាំ២០០៤-១១។ ក្នុងពេលដែលចំណែកនៃពលកម្មកុមារនៅក្រុងភ្នំពេញ និងតំបន់ក្រុងផ្សេងទៀត បានធ្លាក់ចុះអស់ពាក់កណ្ដាលនោះ នៅតំបន់ជនបទវាកើនឡើង ២%។ ម្យ៉ាងទៀត កុមាររស់នៅក្នុងគ្រួសារគ្មានដីធ្លី មានដល់ ១៨% រីឯកុមាររស់នៅក្នុងគ្រួសារមានដីកាន់កាប់ មានត្រឹម ៩%។ ក្នុងចំណោមកុមារដែលធ្វើការ មានត្រឹម ១០% ប៉ុណ្ណោះដែលមិនបានចូលសាលាសោះ, មាន ៨០% ធ្វើការផង និងរៀនផង ហើយ ១០% ទៀតមិនមានចម្លើយបញ្ជាក់ទេ។

វត្តមានពលកម្មកុមារ ឃើញមានញឹកញាប់ជាងក្នុងគ្រួសារមានដីកាន់កាប់ ជាជាងគ្រួសារគ្មានដីធ្លី។ វត្តមានពលកម្មកុមារ វាមានទំនាក់ទំនងជាមួយទំហំដីកាន់កាប់ដែលប្រែប្រួលជុំវិញ កម្រិត ១៩% សម្រាប់គ្រួសារគ្មានដីធ្លី និង កម្រិតមធ្យម (mean) ៣០% (ចាប់ពី ២៤ ទៅ ៣៩%) សម្រាប់គ្រួសារមានដីកាន់កាប់ (តារាង ៣)។ នៅពេលបូកចូលនូវមុខរបរគ្រួសារទាំងអស់ ពលកម្មកុមារឃើញមានច្រើនជាងក្នុងគ្រួសារក្រីក្រ ជាជាងគ្រួសារធូរធារ។

## លទ្ធផលជាក់ស្ដែង

ការប៉ាន់ស្មានតាមម៉ូដែល Probit បង្ហាញថា កុមារក្នុងគ្រួសារគ្មានដីធ្លី មានចូលរួមក្នុងទីផ្សារពលកម្ម តិចជាង កុមារក្នុងគ្រួសារមានដីកាន់កាប់។ លទ្ធផលនេះស៊ីគ្នាជាមួយការសិក្សាពីមុនៗ (Mead 1997; Bhalotra and Heady 2000)។

វត្តមានពលកម្មកុមារ ជាប់ទាក់ទងគួរឲ្យកត់សំគាល់ទៅនឹងកម្រិតអប់រំរបស់មេគ្រួសារ៖ កុមារក្នុងគ្រួសារមានមេគ្រួបានបញ្ចប់យ៉ាងហោចណាស់ថ្នាក់បឋមសិក្សា មានឱកាសតិចជាងនឹងត្រូវបញ្ជូនឲ្យចេញទៅធ្វើការ។ ក្មេងប្រុសទំនងជាចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច ច្រើនជាងក្មេងស្រី។ កត្តារួមចំណែកផ្សេងទៀត មានជាអាទិ៍ ភាពពឹងផ្អែកច្រើនរបស់គ្រួសារទៅលើពលកម្មកុមារដើម្បីរស់រាន និងការរស់នៅក្នុងគ្រួសារធ្វើកសិកម្មនៅជនបទ។

ការប្រើម៉ូដែលដើម្បីប៉ាន់ស្មានពី អន្តរកម្មរវាងពលកម្មកុមារ និងទ្រព្យធនដី បង្ហាញថា គ្រួសារគ្មានដីធ្លីតែងឲ្យកូនចូលរួមក្នុងការងារ តិចជាង គ្រួសារមានដីកាន់កាប់ ទោះបីគាត់ក្រីក្រ ឬធូរធារក្ដី (រូបភាព១)។ ទោះជាយ៉ាងណាក៏ដោយ កុមារក្នុងគ្រួសារក្រីក្របំផុតគ្មានដី មានប្រូបាប៊ីលីតេខ្ពស់ជាង ក្នុងការត្រូវធ្វើការ បើធៀបនឹង កុមារក្នុងគ្រួសារធូរធារបំផុតគ្មានដី។

## លទ្ធផលរកឃើញបែបគុណភាព

មានការខុសប្លែកគ្នាមួយចំនួនរវាង កុមារក្នុងគ្រួសារគ្មានដីធ្លី និងកុមារក្នុងគ្រួសារមានដីកាន់កាប់។ កុមារក្នុងគ្រួសារគ្មានដីធ្លីតែងធ្វើការជាសំខាន់នៅក្នុងស្រែ និងចំការដំណាំលក់យកប្រាក់ដើម្បីបានប្រាក់មកដោះស្រាយតម្រូវការចាំបាច់ ជាពិសេសអាហារ។ ពួកគេទទួលកាងារគ្រប់ប្រភេទ ឲ្យតែបានប្រាក់ឈ្នួលប្រចាំថ្ងៃ។ ឪពុកម្ដាយមានពេលតិចនៅមើលថែទាំកុមារ នៅពេលកុមារកំពុងត្រូវការពួកគាត់ខ្លាំងបំផុត។ កុមារត្រូវបាត់បង់ឱកាសបានទៅរៀនទៀងទាត់ ព្រោះគ្មានចំណីអាហារ, សម្ភារសិក្សាសមស្រប ឬមធ្យោបាយធ្វើដំណើរ។ អ្នកខ្លះត្រូវតាមឪពុកម្ដាយទៅធ្វើការនៅគ្រប់កន្លែង។

រូបភាព១: ពលកម្មកុមារក្នុងក្រុមបញ្ចភាគទ្រព្យធនដីទី១ (ឆ្វេង) និង ទី៥ (ស្ដាំ) នៅឆ្នាំ២០០៤-១១




Source: CSES 2004-11

កុមារក្នុងគ្រួសារមានដីកាន់កាប់ ជារឿយៗត្រូវធ្វើការក្នុងកសិដ្ឋានគ្រួសារ ឬក្នុងរបរជំនួញរបស់គ្រួសារ នៅពេលពួកគេមិនទៅសាលា។ ឪពុកម្តាយត្រួតពិនិត្យកុមារទាំងនេះយ៉ាងដិតដល់ និងមិនទុកឲ្យធ្វើការតែឯងទេ ហើយការងារធ្ងន់ៗគាត់ជួលពលករមកធ្វើ។ កុមារមានអាហារគ្រប់គ្រាន់ និងរបស់ចាំបាច់ដទៃទៀត ទោះបីពួកគេធ្វើការ ឬមិនធ្វើការក្តី។ អ្នកខ្លះរៀនចប់ថ្នាក់ទី១២ ឬថ្នាក់មហាវិទ្យាល័យ រីឯអ្នកខ្លះទៀតឈប់រៀន ហើយផ្តោតកម្លាំងក្នុងរបរជំនួញរបស់គ្រួសារ។

ឪពុកម្តាយ មនុស្សពេញវ័យ និងចាស់ទុំក្នុងគ្រួសារ មានឥទ្ធិពលខ្លាំងបំផុតទៅលើជីវិត និងសកម្មភាពសេដ្ឋកិច្ច របស់កុមារ។ក្មេងប្រុសដឹងថាត្រូវធ្វើតាមឪពុករបស់ខ្លួនដោយធ្វើការងារធ្ងន់ៗភាគច្រើន ដូចជា កាប់ឈើ និងឫស្សី គាស់ដំឡូង ភ្ជួរស្រែ ប្រមូលចំបើង ។ល។ ក្មេងស្រីទទួលការងាររបស់ម្តាយ ដែលគេចាត់ទុកជាការងារស្រាល ដូចជា មើលក្មេង ចិតដំឡូងហាល ស្ទូង ជម្រះស្មៅ ប៉ាក់ខ្មៅយ និងត្បាញកន្ទេល។ល។

## សេចក្តីសន្និដ្ឋាន

ភាពគ្មានដីធ្លី និងពលកម្មកុមារក្នុងគ្រួសារធ្វើកសិកម្ម មានទំនាក់ទំនងជាមួយគ្នា។ កុមារក្នុងគ្រួសារគ្មានដីធ្លីដែលត្រូវធ្វើការតែងមានតិចនាក់ជាង កុមារក្នុងគ្រួសារមានដីកាន់កាប់ដែលត្រូវធ្វើការ ព្រោះពួកគេមានឱកាសតិចជាង ដើម្បីធ្វើការងារតាមរដូវកាលនៅជនបទ និងខ្វះខាតធនធានដើម្បីទៅស្វែងរកការងារនៅកន្លែងផ្សេង។

កុមារក្នុងគ្រួសារក្រីក្រគ្មានដីធ្លី តែងមានចូលរួមធ្វើការងារច្រើននាក់ជាង កុមារក្នុងគ្រួសារធូធារគ្មានដីធ្លី។ កត្តាដែលជួយកាត់បន្ថយបញ្ហាពលកម្មកុមារ គឺកម្រិតអប់រំរបស់មេគ្រួសារ និងវត្តមានមនុស្សពេញវ័យច្រើនក្នុងគ្រួសារ។ ការរស់នៅក្នុងគ្រួសារធ្វើកសិកម្ម ការមានកុមារច្រើនអាយុ០-៤ឆ្នាំក្នុងគ្រួសារ និង ការរស់នៅក្នុងតំបន់ជនបទ គឺជា កត្តាសំខាន់ៗដែលរួមចំណែកធ្វើឲ្យមានពលកម្មកុមារ។

យោបល់មួយចំនួនដូចខាងក្រោម អាចជួយរំដោះកុមារពីភាពចាំបាច់ត្រូវធ្វើការ៖

- ជួយឲ្យគ្រួសារធ្វើកសិកម្ម កាន់តែមានលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាសំចៃពលកម្ម
- បំផុសឲ្យគ្រួសារយល់ពីសារៈសំខាន់នៃ ការអប់រំដែលមានតម្លៃយូរអង្វែង
- ដាក់បញ្ចូលជំនាញអនុវត្តជាក់ស្តែងទៅក្នុងប្រព័ន្ធអប់រំ
- ចាប់អនុវត្តកាលវិភាគអាចបត់បែនបាន នៅតាមសាលារៀន
- ផ្តល់សន្តិសុខស្បៀង ដល់ក្រុមគ្រួសាររបស់កុមារក្រីក្រ តាមការកែលំអលទ្ធភាពមានដីដាំដុះ
- ពង្រឹងជំនាញបំពេញតួនាទីជាឪពុកម្តាយ
- ផ្តល់នូវសម្ភារសិក្សា ឯកសណ្ឋាន និង មធ្យោបាយធ្វើដំណើរ។

## ឯកសារយោង


Bhalotra, Sonia. 2000. *Is Child Work Necessary?* London: Suntory Centre.

Bhalotra, Sonia and Christopher Heady. 2000. *Child Farm Labour: Theory and Evidence.* London: Suntory Centre.

Bhalotra, Sonia and Christopher Heady. 2003. "Child Farm Labour: The Wealth Paradox." *World Bank Economic Review* 17(2): 197-227.

Emerson, M. Patric, and Andre Portela Souza. 2003. *Is There a Child Labour Trap? Intergenerational Persistence of Child Labour in Brazil.* Working Paper 02-W14. Nashville: Department of Economics, Vanderbilt University.

ILO (International Labour Organization). 2002. *Eliminating the Worst Forms of Child Labour: A Practical Guide to ILO Convention No. 182*. Handbook for Parliamentarians No. 3. Geneva: ILO.

Khan, Himayatullah. 2007. "Child Labour in Pakistan and Other Developing Countries." *RevistaTinerilorEconomisti* 1(8): 121-132.

Mead, Cain, T. 1977. "The Economic Activities of Children in a Village in Bangladesh." *Population and Development Review* 3(3): 201-227.

Ministry of Planning. 2012. "2012 Annual Progress Report." Phnom Penh: MOP.

NIS (National Institute of Statistics). "Cambodia Socio-Economic Survey (2004, 2007-2011)." Unpublished data.

NIS and ILO. 2013. *Cambodia Labour Force and Child Labour Survey 2012: Child Labour Report.* ILO International Programme on the Elimination of Child Labour. Phnom Penh: ILO.

Phann Dalis, Tong Kimsun, Phay Sokcheng and Pon Dorina. 2014. "Landlessness and Child Labour in Cambodia." Final Report. www.cdri.org.kh/Landlessness%20and%20Child%20Labour_CDRI_2015.pdf.

Siddiqui, A.B. 2012. "An Analytical Study of Child Labour—An Exploitation and Not Employment." *International Journal of Advanced Research in Management and Social Sciences* 1(3).